**សិក្ខាសាលាស្តីពីលទ្ធផលនៃការស្ទង់មតិជាមូលដ្ឋានលើ សមត្ថភាពតាក់តែងច្បាប់របស់**
**អង្គភាពនីតិកម្ម នៃ ក្រសួងឬស្ថាប័ន**
**ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៩**
**សណ្ឋាគារ ណាហ្គាវើលដ៍**

**សុន្ទរកថាបើកសិក្ខាសាលាស្តីពីលទ្ធផលនៃការស្ទង់មតិជាមូលដ្ឋានលើ សមត្ថភាពតាក់តែងច្បាប់របស់ អង្គភាពនីតិកម្មនៃក្រសួងឬស្ថាប័ន ដោយ ឯកឧត្តម ស៊ុយ ម៉ុងលាង អគ្គលេខាធិការនៃ អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ និង ជាប្រធានក្រុមការងារបច្ចេកទេសចំរុះកំណែទម្រង់ច្បាប់និងតុលាការ**

- ឯកឧត្តម លោកជំទាវ
- **លោកស្រី Katharina Hubner,** មន្ត្រីកម្មវិធី- កំណែទម្រង់រដ្ឋបាល និង វិមជ្ឈការ របស់កម្មវិធី កិច្ចសហប្រតិបត្តិការ អាឡឺម៉ង់ដ៏ (GTZ)
- លោក លោកស្រី និងភ្ញៀវកិត្តិយសទាំងអស់ ជាទីគោរពរាប់អាន

តាងនាម **អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែ ទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌** ខ្ញុំ សូមថ្លែងអំណរគុណ ដ៏ជ្រាលជ្រៅ ចំពោះវត្តមានរបស់ ឯកឧត្តម អស់លោក លោកស្រី និងភ្ញៀវកិត្តិយសទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងសិក្ខាសាលាស្តីពី "លទ្ធផលនៃការស្ទង់មតិជាមូលដ្ឋានលើសមត្ថភាពតាក់តែងច្បាប់របស់អង្គភាពនីតិកម្ម នៃ ក្រសួងឬស្ថាប័ន" ដ៏មាន សារៈសំខាន់នាថ្ងៃនេះ ដែលជាដំណាក់បន្តពី "សិក្ខាសាលាណែនាំស្តីពីការស្ទង់មតិជាមូលដ្ឋានលើ សមត្ថភាព តាក់តែងច្បាប់របស់អង្គភាពនីតិកម្ម នៃ ក្រសួងឬស្ថាប័ន" លើកទី១ ដែលបានរៀបចំឡើងកាលពីថ្ងៃទី ២៣ ខែមករា ឆ្នាំ ២០០៩កន្លងមកនេះ។

ឯកឧត្តម អស់លោក លោកស្រី និងភ្ញៀវកិត្តិយសទាំងអស់បានជ្រាបរួចហើយថា យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការកម្ពុជាបានទទួលការអនុម័តកាលពីថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៣ ដោយគណៈរដ្ឋមន្ត្រី ហើយកម្មវិធីសកម្មភាព អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងតុលាការ ក៏ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ តាំងពីថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៥មកដែរ។ក្នុងចំណោមផែនការសកម្មភាពចំនួន ៩៧នោះ មានផែនសកម្មភាពលេខ ២.៣.៤ ដែល ពាក់ព័ន្ធនឹងការពង្រឹងសមត្ថភាពនៃអង្គភាពនីតិកម្មរបស់ក្រសួងនីមួយៗ។

ការពង្រឹងសមត្ថភាពនៃអង្គភាពនីតិកម្មរបស់ក្រសួងនីមួយៗអាចសម្រេចទៅបានលុះត្រាណាយើងបានស្វែងយល់ពីស្ថានភាពបច្ចុប្បន្ន សេចក្តីត្រូវការ និង ការផ្គត់ផ្គង់របស់អង្គភាពនីតិកម្មនាជាមុនសិន។ ហេតុនេះហើយបានជា យើង

ចាំបាច់ត្រូវធ្វើការស្ទង់មតិជាមូលដ្ឋាន លើអង្គភាពនីតិកម្ម និង សមត្ថភាពតាក់តែងច្បាប់របស់ក្រសួងឬស្ថាប័ន ជាមុនសិន មុននឹងយើងអាចធ្វើផែនការរួមដើម្បី ពង្រឹងសមត្ថភាពនៃអង្គភាពនីតិកម្មនៅតាមក្រសួងនានា។

ដោយមានការគាំទ្រពីកម្មវិធីសហប្រតិបត្តិការអាឡឺម៉ង់ជី(GTZ) អង្គភាពគ្រប់គ្រងគម្រោងដែលឥឡូវនេះ បានក្លាយទៅជាអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែ ទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌បានរៀបចំនូវការស្ទង់មតិជាមូលដ្ឋាន លើអង្គភាពនីតិកម្មនិងសមត្ថភាពតាក់តែងច្បាប់របស់ក្រសួងឬស្ថាប័ននេះឡើង។ ការស្ទង់មតិមតិមានគោលដៅស្វែងយល់លើ បញ្ហាសំខាន់ៗមួយចំនួន ៤ គឺៈ (១) ស្ថានភាព បច្ចុប្បន្នលើការតាក់តែងច្បាប់ និង ស្ថាប័នដែលពាក់ព័ន្ធក្នុងដំណើរការតាក់តែងច្បាប់(ដូចជាក្រមខណ្ឌច្បាប់, យន្តការតាក់ តែងច្បាប់គោលការណ៍ណែនាំទាក់ទងនឹងការតាក់តែងច្បាប់ និង ធនធាននៃការតាក់តែងច្បាប់ជាដើម ), (២) សេចក្តីត្រូវការដើម្បីបំពេញសមត្ថភាពនៃការតាក់តែងច្បាប់របស់ អង្គភាពនីតិកម្ម,(៣)ការផ្តត់ផ្គង់ដើម្បី បំពេញសមត្ថភាពនៃការតាក់តែងច្បាប់របស់អង្គភាពនីតិកម្ម, និង (៤) វិធាការ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពនៃការតាក់តែងច្បាប់របស់អង្គភាពនីតិកម្ម។ ការស្ទង់មតិនេះនេះបានឈានដល់ដំណាក់កាលបញ្ចប់ បន្ទាប់ពីធ្វើ ការសិក្សាស្រាវជ្រាវអស់រយៈពេលជាង ១០ ខែកន្លងមក។

សិក្ខាសាលាថ្ងៃនេះត្រូវបានរៀបចំឡើងដើម្បីបង្ហាញជូននូវលទ្ធផលនៃ ការស្ទង់មតិជាមូលដ្ឋានលើ សមត្ថភាព តាក់តែងច្បាប់របស់អង្គភាពនីតិកម្មនៃ ក្រសួងឬស្ថាប័ន" និងប្រមូលអនុសាសន៍បន្ថែមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ដើម្បីយកមកពិចារណានិងធ្វើការបញ្ចូលទៅក្នុងរបាយការណ៍នៃការស្ទង់មតិនេះ ដើម្បីធ្វើជាមូលដ្ឋាន ក្នុងការកំណត់នូវផែនការយុទ្ធសាស្ត្រមួយក្នុងការពង្រឹង និងធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពតាក់តែងច្បាប់របស់អង្គភាពនីតិកម្មនៃក្រសួងឬស្ថាប័ន។ ហេតុនេះហើយការចូលរួមពិភាក្សាផ្តល់យោបល់ របស់ ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់មិនត្រឹមតែចូលរួមចំណែកក្នុងការពង្រឹងនិងធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពតាក់តែង ច្បាប់របស់អង្គភាពនីតិកម្មនៃ ក្រសួងឬស្ថាប័នប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចូលរួម ចំណែកពង្រឹងនីតិរដ្ឋនៅកម្ពុជា ស្រប តាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលផងដែរ។

ជាទីបញ្ចប់ខ្ញុំសូមសំដែងនូវអំណរគុណជាថ្មីម្តងទៀត ចំពោះឯកឧត្តម អស់លោក លោកស្រី និងភ្ញៀវកិត្តិយសទាំងអស់ដែល មានវត្តមានក្នុង អង្គសិក្ខាសាលានេះ និងសូមប្រសិទ្ធិពរអោយអង្គសិក្ខាសាលាទាំងមូល ទទួលបាន ជោគជ័យ ក្នុងការពិភាក្សា និង សូមប្រកាសបើកអង្គសិក្ខាសាលានេះចាប់ពីពេលនេះតទៅ។

សូមអរគុណ